ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៥៨ ត្រីមាសទី០៣ឆ្នាំ២០២១

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៦-១០-២០២១	-ព្រះរាជក្រម នស/រកម/១០២១/០១៥ ស្ដីពី ការប្រកាសឱ្យប្រើច្បាប់ស្ដីពី វិសោធនកម្មមាត្រា១៨ថ្មី នៃច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា	៧០៨៩

២~ព្រះរាជក្រឹត្យ

១៥-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៣៧ ស្ដីពី ការតាំងស៊ប់ នៃក្របខណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដល់មន្ត្រីរាជការ ២ រូប	៧០៩២
១៥-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៣៨ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសសហមេត្រី ថ្នាក់ មហាសេនា ចំពោះ លោកបណ្ឌិត **យុន យុងហូ** (Yun Young-ho)	៧០៩៣
១៥-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៣៩ ស្ដីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយសដល់មន្ត្រីរាជការនៃក្រសួងបរិស្ថាន ៣៧រូប	៧០៩៤
១៩-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៤០ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈឯកឧត្តម **អ៊ុខ សំអាត** ជាទីប្រឹក្សាផ្ទាល់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ	៧០៩៦
៩-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៤១ ស្ដីពី ការតម្លើងឋានៈដល់ឯកឧត្តម **ម៉ាខ ស៊ីណេត** ជំនួយការសម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រ-កម្ពុជា មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន	៧០៩៧
១៩-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៤២ ស្ដីពី ការបញ្ចប់មុខតំណែង ពីអនុប្រធាន និងសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ៤ រូប	៧០៩៨
១៩-១០-២០២១	-ព្រះរាជក្រឹត្យ នស/រកត/១០២១/៧៤៣ ស្ដីពី ការតែងតាំង និងផ្ដល់ឋានៈ ជាសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១២ រូប និងតែងតាំង និងតម្លើងឋានៈសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ៦ រូប	៧០៩៩

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

២០-៨-២០២១	-អនុក្រឹត្យលេខ ១៥៦ អនក្រ.បក ស្ដីពី ការបង្កើតសង្កាត់អូរជ្រៅ នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ	៧១០១

២០-៨-២០២១	-អនុក្រឹត្យលេខ ១៥៧ អនក្រ.បក ស្តីពី ការបង្កើតសង្កាត់អូរឫស្សី នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ	៧១០៤
១៩-១០-២០២១	-អនុក្រឹត្យលេខ ៤៩៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៧១០៧
១៩-១០-២០២១	-អនុក្រឹត្យលេខ ៤៩៥ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៧១០៩
១៩-១០-២០២១	-អនុក្រឹត្យលេខ ៤៩៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ	៧១១១
១៩-១០-២០២១	-អនុក្រឹត្យលេខ ៤៩៧ អនក្រ.តត ស្តីពី ការជូនមេដាយការងារ	៧១១២
១៩-១០-២០២១	-អនុក្រឹត្យលេខ ៤៩៨ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ	៧១១៤

III~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

៥-២-២០២១	-ប្រកាសលេខ ០៤៣ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៉ូលីមើ ប្លាស្ទិក ប្រដាក់ បង្កើតរោងចក្រ ផលិតធុងទឹកកក	៧១១៦
៨-២-២០២១	-ប្រកាសលេខ ០៤៤ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឡាក់ សាន់ (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ខារអំបោះគ្រប់ប្រភេទ	៧១១៩
៨-២-២០២១	-ប្រកាសលេខ ០៤៧ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ ឌុមប៊ី (ខេមបូឌា) បង្កើតរោងចក្រ ផលិតសម្ភារៈក្មេងលេង ប្លាស្ទិក និងកាត់ដេរសម្លៀកបំពាក់	៧១២២
៨-២-២០២១	-ប្រកាសលេខ ០៤៨ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជា ហូ (ខេមបូឌា) ហ្គាម៉ិន អ៊ិនដាសស្ទ្រៀល បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់	៧១២៥
១០-២-២០២១	-ប្រកាសលេខ ០៤៩ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ណាហ្គាភីស ឧបភើរេសិន បង្កើតរោងចក្រ កាត់ដេរ បោកគក់សម្លៀកបំពាក់ ផលិតថង់យួរ និងកាបូបគ្រប់-ប្រភេទ	៧១២៨
១០-២-២០២១	-ប្រកាសលេខ ០៥១ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អ្យ៉ូថាម ញូ មេធៀរៀល ឯ.ក បង្កើតរោងចក្រ ផលិតសារធាតុ Vanadium Pentoxide, Ammonium Metavanadate, Molybdenum Oxide and Ferronickle	៧១៣១
១០-២-២០២១	-ប្រកាសលេខ ០៥២ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ឈួស ផលីយូរីសេន មេធៀរៀល (ខេមបូឌា) បង្កើតរោងចក្រ ផលិតពូក និងអេប៉ុងហ្ស៍	៧១៣៤
១១-២-២០២១	-ប្រកាសលេខ ០៥៣ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យីនស៊ីង (ខេមបូឌា) ហ៊ែនប៊ែក & អេកសេស៊ីរី ឯ.ក បង្កើតរោងចក្រ ផលិតម៉ាស់ និងកាបូបគ្រប់ប្រភេទ	៧១៣៧

១១-២-២០២១ -ប្រកាសលេខ ០៥៤ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន វ៉ូណាមមី (ខេមបូឌា) ហ្គាមេន បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧១៤០

១១-២-២០២១ -ប្រកាសលេខ ០៥៦ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គោលឌិន ចេន ប្លាស្ទិក អ៊ិនដាសស្ទ្រី (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតស្បែកជើង និងគ្រឿងបន្សំស្បែកជើង ៧១៤៣

១២-២-២០២១ -ប្រកាសលេខ ០៥៧ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ៊ែលសា សៅ អ៊ិស អេស៊ា ខូ អិលធីឌី បង្កើតរោងចក្រ ផលិតប៉ុងស្មាអាវ ៧១៤៦

១២-២-២០២១ -ប្រកាសលេខ ០៥៨ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប៊ីជេស៊ី សែលទ្បុកស៍ (ខេមបូឌា) ខូ អិលធីឌី ឯ.ក បង្កើតរោងចក្រ ផលិតក្រដាសអនាម័យ ៧១៤៩

១៥-២-២០២១ -ប្រកាសលេខ ០៦០ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហាវេស ស្រ្តេដ ផេភើរ បង្កើតរោងចក្រ ផលិតកេសកាតុង ៧១៥២

១៥-២-២០២១ -ប្រកាសលេខ ០៦២ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ប្រាយនេស (ខេមបូឌា) ហ្គាម៉ិន ហ្វេកធើរី ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៧១៥៥

១៦-២-២០២១ -ប្រកាសលេខ ០៧២ ឧវបន.កឧ.ប្រក ២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្គ្រេនឌី ក្រាហ្វ បង្កើតរោងចក្រ ផលិតវត្ថុអនុស្សាវរីយ៍គ្រប់ប្រភេទ ៧១៥៨

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល

១-១០-២០២០ -ប្រកាសលេខ ០៣៨៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៨៥ រថ.អប្រក.លអ ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២០ ៧១៦១

១-១០-២០២០ -ប្រកាសលេខ ០៣៨៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៨៦ រថ.អប្រក.លអ ចុះថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២០ ៧១៦៥

៦-១០-២០២០ -ប្រកាសលេខ ០៣៨៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៨៧ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០ ៧១៦៩

៦-១០-២០២០ -ប្រកាសលេខ ០៣៩០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩០ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០ ៧១៧៣

៦-១០-២០២០ -ប្រកាសលេខ ០៣៩១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩១ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០ ៧១៧៧

៦-១០-២០២០ -ប្រកាសលេខ ០៣៩២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩២ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០ ៧១៨១

៦-១០-២០២០	-ប្រកាសលេខ ០៣៩៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩៣ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០	៧១៨៥
៦-១០-២០២០	-ប្រកាសលេខ ០៣៩៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩៥ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០	៧១៨៩
៦-១០-២០២០	-ប្រកាសលេខ ០៣៩៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩៦ រថ.អប្រក.លអ ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០២០	៧១៩៣
៨-១០-២០២០	-ប្រកាសលេខ ០៣៩៧ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការមណ្ឌលសន្និធិប្រេងឥន្ធនៈលេខ ០៣៩៧ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០២០	៧១៩៧
៨-១០-២០២០	-ប្រកាសលេខ ០៣៩៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយប្រេងឥន្ធនៈលេខ ០៣៩៨ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០២០	៧២០១
៨-១០-២០២០	-ប្រកាសលេខ ០៣៩៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៣៩៩ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០២០	៧២០៥
១៣-១០-២០២០	-ប្រកាសលេខ ០៤០៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៤០៣ រថ.អប្រក.លអ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២០	៧២០៩

ព្រះរាជក្រម

នស/រកម/១០២១/០១៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១ នាសម័យប្រជុំពេញអង្គលើកទី៧ នីតិកាលទី៤ ព្រមទាំងមានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ២១៤/០០១/២០២១ ក.ប/ប្រ.ច ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា១៨ថ្មី
នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨
នៃច្បាប់ស្តីពីសវនកម្ម
នៃព្រះរាជាណាចក្រកម្ពុជា

មាត្រាមួយ .-

មាត្រា១៨ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៦/០២៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ត្រូវបានធ្វើវិសោធនកម្ម ដូចតទៅ៖

មាត្រា១៨ .- ថ្មី(ពីរ)

អគ្គសវនករនិងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាលនិង ដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

អគ្គសវនករនិងអគ្គសវនកររង នឹងត្រូវបានទទួលការតែងតាំងសម្រាប់អាណត្តិ៥(ប្រាំ)ឆ្នាំ ហើយអាច ទទួលការតែងតាំងជាថ្មី។

ក្នុងករណីដែលអគ្គសវនករឬអគ្គសវនកររងទទួលអនិច្ចកម្មឬលាលែងឬបាត់បង់សមត្ថភាពពលកម្មឬ មានកំហុសជាទម្ងន់នោះ ត្រូវជ្រើសតាំងអគ្គសវនករឬអគ្គសវនកររងថ្មីជំនួសតាមលក្ខខណ្ឌដែលបានកំណត់ ក្នុងច្បាប់នេះ។

អគ្គសវនករមានឋានៈនិងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈនិងបុព្វសិទ្ធិស្មើនឹង រដ្ឋមន្ត្រី។

មាត្រាពីរ .-

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ១០កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៦ ខែ តុលា ឆ្នាំ២០២១

នស/រកម.១០២១.០១៤

(ហត្ថលេខា) ន សីហមុនី

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

(ហត្ថលេខា)

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

(ហត្ថលេខា)

អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

(ត្រា និង ហត្ថលេខា)

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

៣/៣

ព្រះរាជក្រឹត្យ

នស/រកត/១០២១/៩៩៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តាំងស៊ប់ ទៅក្នុងឋានន្តរស័ក្តិមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដល់មន្ត្រីរាជការ ០២ រូប ចាប់ពីថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០២១៖

១-លោក **តាន់ ជីខាន់**	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤
២-លោក **ឡុង សេរីវឌ្ឍនៈ**	មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៤

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរស.២១១០.៧៥០

នសីហមុនី

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០២១

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

ជូន

គ្រឿងឥស្សរិយយស **សហមេត្រី** ថ្នាក់ **មហាសេនា**

ចំពោះ

លោកបណ្ឌិត **យុន យុងហូ** (Yun Young-ho)

នរោត្តម សីហមុនី

៣១៧.២២១០.៧៦៦

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០២១

បានយកសេចក្តីគោរពក្រាបបង្គំទូលថ្វាយ
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៧៣៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(តាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ដល់មន្ត្រីរាជការនៃក្រសួងបរិស្ថាន ៣៧រូប៖

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម	ជា ចន្ទន៍ជូ	៣-លោក	អ៊ូ ច័ន្ទជារិទ្ធ
២-លោក	គុជ កុសល	៤-លោក	អេង ភីរុង

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម	សាបូ អូហ្សាណូ	៥-លោក	ខ្មៃ អាទិត្យា
២-ឯកឧត្តម	គង់ វិចិត្រ	៦-លោក	ដាញ់ សេរី
៣-លោក	ទេស សំណាង	៧-លោក	ឆយ ម៉ុនលី
៤-លោក	ស៊ី វ៉ាមុនី		

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-លោកជំទាវ	ម៉ុម ថានី	៤-លោក	ចាន់ ពុទ្ធារិទ្ធ
២-លោក	ភិន ណារ៉ុង	៥-លោកស្រី	សេង ប៊ុណ្ណារិទ្ធ
៣-លោក	ស៊ុយ ឆា	៦-លោក	សំ គល់

ឃ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា :

១-លោក	ស៊ាង ដាធី	២-លោក	ឃួន តារា

ង-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម	ម៉េង មុនីរក្ស	៣-លោក	ឆាយ ចន្ថន
២-លោកស្រី	ថៃ សីលាទីណា		

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ច-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

១-ឯកឧត្តម គិត ច័ន្ទត្រីស្នា	៧-លោកស្រី ព្រហ្ម ច័ន្ទសីម៉ា
២-លោក សេង សោត	៨-លោកស្រី ចាន់ គុជមុន្នីមុំ
៣-លោក សេង សុលៀម	៩-លោក ទា ធីរោ
៤-លោក ជិន ថាវ៉ូ	១០-លោក ម៉ុក សុភា
៥-លោក សេក ជា	១១-លោក ស៊ីវ គង់
៦-លោកស្រីផល្លី ភិមាន	

ឆ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ :

១-ឯកឧត្តម ម៉ៅ វិបុល	៣-លោក ស្វាយ ស៊ីថាវិច្ចិកា
២-ឯកឧត្តមសេន ណាស៊ី	៤-លោក ឡុង ស្រេង

នស/រកត.១០២១.៧៥២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៥ ខែតុលា ឆ្នាំ ២០២១

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៤០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម / ០៦១៨ / ០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង និងផ្តល់ឋានៈឯកឧត្តម **អ៊ុង សំអាត** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ដោយពុំទទួលប្រាក់បំណាច់មុខងារ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

នរោត្តម សីហមុនី

ពរស. ២១១០.៧៥៥

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៤១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រង និងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: តម្លើងឋានៈដល់ឯកឧត្តម **ម៉ាង ស៊ុំណាត** ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ពរល.៤១១០.៧៥៦

នរោត្តម សីហមុនី (ហត្ថលេខា)

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២១/១៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំជាថ្មីនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: បញ្ចប់មុខតំណែង ពីអនុប្រធាន និងសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ៤រូបៈ

១- ឯកឧត្តម **ឌឹម សុវណ្ណារុំ**
២- ឯកឧត្តម **ស្រ៊ុន ធីរិទ្ធ**
៣- លោកជំទាវ **ស៊ីន ទូលែរ**
៤- ឯកឧត្តម **ម៉ែន សេង** ។

មាត្រា ២: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នរោត្តម សីហមុនី

ការស.២១១០.៧៤៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០២១

នរោត្តម សីហមុនី

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជក្រឹត្យ

នស/រកត/១០២១/៧៤៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំជាថ្មីនៃគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង និងផ្តល់ឋានៈ ជាសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ១២រូប៖

១-	ឯកឧត្តម	**សៅ សុគៈ**	មានឋានៈស្មើអនុរដ្ឋលេខាធិការ
២-	ឯកឧត្តម	**ទេព មុនីជាតិ**	មានឋានៈស្មើអនុរដ្ឋលេខាធិការ
៣-	ឯកឧត្តម	**ស៊ិន ម៉ុនធឿន**	មានឋានៈស្មើអនុរដ្ឋលេខាធិការ
៤-	ឯកឧត្តម	**អូ ចិន្តា**	មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន
៥-	លោកជំទាវ	**លឹម ច័ន្ទលីដា**	មានឋានៈស្មើអនុរដ្ឋលេខាធិការ
៦-	ឯកឧត្តម	**ប៉ាល់ ឆិត្យថិរៈ**	មានឋានៈស្មើអគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន
៧-	លោកជំទាវ	**ម៉ូ ស៊ូវ៉ានី**	មានឋានៈស្មើអគ្គនាយក
៨-	លោកជំទាវ	**មួង សគុណា**	មានឋានៈស្មើអគ្គនាយក
៩-	លោកជំទាវ	**ដារ៉ា សុគន្ធា**	មានឋានៈស្មើអគ្គនាយក
១០-	ឯកឧត្តម	**សុភារិន វាស្នា**	មានឋានៈស្មើអគ្គនាយក
១១-	លោកជំទាវ	**ម៉េង មុនីរត្ន**	មានឋានៈស្មើអគ្គនាយក
១២-	ឯកឧត្តម	**សរ សន**	មានឋានៈស្មើអគ្គនាយក។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

មាត្រា ២: តែងតាំង និងតម្លើងឋានៈសមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ៦រូប៖

១- លោកជំទាវ **អ៊ុច និពន្ធ** មានឋានៈស្មើរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន

២- លោកជំទាវ **ឆាំ ម៉ារី** មានឋានៈស្មើរដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **អ៊ុំ ណារិទ្ធ** មានឋានៈស្មើអនុរដ្ឋលេខាធិការ

៤- ឯកឧត្តម **គាំ ច័ន្ទមុន្នី** មានឋានៈស្មើអនុរដ្ឋលេខាធិការ

៥- ឯកឧត្តម **លឹម ឡេង** មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន

៦- ឯកឧត្តម **ជិន អង្គារិទ្ធិ** មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន។

មាត្រា ៣: សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នស/រកត.១០២១.៧៥៩

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០២១

នរោត្តម សីហមុនី

នរោត្តម សីហមុនី

បានបម្លងត្រឹមត្រូវតាមច្បាប់ដើម

ឧបនាយករដ្ឋមន្ត្រីប្រចាំការ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

គណៈរដ្ឋ

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតសង្កាត់អូរជ្រៅ នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបង្កើត **សង្កាត់អូរជ្រៅ** នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយកាត់យកភូមិចំនួន០៧ ពីសង្កាត់ប៉ោយប៉ែត គឺភូមិអូរជ្រៅ ភូមិក្បាលកោះ ភូមិក្បាលស្ពាន១ ភូមិក្បាលស្ពាន២ ភូមិសាមគ្គីមានជ័យ ភូមិព្រៃព្រិច និងភូមិប៉ោយប៉ែត។

មាត្រា ២.-

សង្កាត់អូរជ្រៅ មានភូមិចំនួន០៧ គឺភូមិអូរជ្រៅ ភូមិក្បាលកោះ ភូមិក្បាលស្ពាន១ ភូមិក្បាលស្ពាន២ ភូមិសាមគ្គីមានជ័យ ភូមិព្រៃព្រិច និងភូមិប៉ោយប៉ែត។

ព្រំប្រទល់រដ្ឋបាលនៃសង្កាត់អូរជ្រៅ ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៣.-

ទីតាំងសាលាសង្កាត់អូរជ្រៅ ស្ថិតនៅក្នុងភូមិព្រៃព្រិច។

មាត្រា ៤.-

ការបង្កើតសង្កាត់អូរជ្រៅ ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិទី៥ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត ត្រូវបន្តគ្រប់គ្រងភូមិចំនួន០៧ គឺភូមិអូរជ្រៅ ភូមិក្បាលកោះ ភូមិក្បាលស្ពាន១ ភូមិក្បាលស្ពាន២ ភូមិសាមគ្គីមានជ័យ ភូមិព្រៃព្រិច និងភូមិប៉ោយប៉ែត រហូតដល់មានក្រុមប្រឹក្សាសង្កាត់អូរជ្រៅ មកជំនួស។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ គណៈអភិបាលខេត្តបន្ទាយមានជ័យ ក្រុមប្រឹក្សាក្រុងប៉ោយប៉ែត គណៈអភិបាលក្រុងប៉ោយប៉ែត ក្រុមប្រឹក្សាសង្កាត់ប៉ោយប៉ែត និងក្រុមប្រឹក្សាសង្កាត់អូរជ្រៅ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ *សុក្រ ១២ កើត ខែ ស្រាពណ៍* ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៦
-រាជកិច្ច
-ឯកសារកាលប្បវត្តិ



Point	Northing(m)	Easting(m)
A	1516622.504	240260.773
B	1514942.928	241569.103
C	1514545.174	241597.592
D	1514274.821	241057597
E	1513928.756	240124.148
F	1512906.918	240299.153
G	1512326.914	240123.791
H	1512381.526	238317.450
I	1511516.448	238329.198
J	1509908.129	237322.972
K	1509975.808	237239.129
L	1509692.584	237002.696
M	1511523.610	234816.727
N	1515289.206	238053.281

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតសង្កាត់អូរបីជ្រៀ នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបង្កើត **សង្កាត់អូរឫស្សី** នៃក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ដោយកាត់យកភូមិចំនួន០៥ ពីសង្កាត់ផ្សារកណ្តាល គឺភូមិអូរឫស្សី ភូមិប្រជាធម្មកើត ភូមិទួលពង្រ ភូមិអូរនាង និងភូមិព្រៃគុប។

មាត្រា ២.-

សង្កាត់អូរឫស្សី មានភូមិចំនួន០៥ គឺភូមិអូរឫស្សី ភូមិប្រជាធម្មកើត ភូមិទួលពង្រ ភូមិអូរនាង និងភូមិព្រៃគុប។

ព្រំប្រទល់រដ្ឋបាលនៃសង្កាត់អូរឫស្សី ត្រូវបានកំណត់ដូចមានក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ៣.-

ទីតាំងសាលាសង្កាត់អូរឫស្សី ស្ថិតនៅក្នុងភូមិទួលពង្រ។

មាត្រា ៤.-

ការបង្កើតសង្កាត់អូរឫស្សី ត្រូវចូលជាធរមានសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នាអាណត្តិទី៥ ស្របតាមខ្លឹមសារមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់។

ក្រុមប្រឹក្សាសង្កាត់ផ្សារកណ្តាល ត្រូវបន្តគ្រប់គ្រងភូមិចំនួន០៥ គឺភូមិអូរឫស្សី ភូមិប្រជាធម្មកើត ភូមិទួលពង្រ ភូមិអូរនាង និងភូមិព្រៃគុប រហូតដល់មានក្រុមប្រឹក្សាសង្កាត់អូរឫស្សី មកជំនួស។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ គណៈអភិបាលខេត្តបន្ទាយមានជ័យ ក្រុមប្រឹក្សាក្រុងប៉ោយប៉ែត គណៈអភិបាលក្រុងប៉ោយប៉ែត ក្រុមប្រឹក្សាសង្កាត់ផ្សារកណ្តាល និងក្រុមប្រឹក្សាសង្កាត់អូរឫស្សី ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ កើត ខែ ស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- រាជកិច្ច
- ឯកសារកាលប្បវត្តិ



Projection UTM, Zone 48N, Datum WGS84		
Point	Northing(m)	Easting(m)
A	1516623.668	240260.442
B	1518324.014	243436.737
C	1517408.810	246168.253
D	1515324.700	246218.323
E	1512807.794	246323.924
F	1511336.525	246530.042
G	1507934.390	246742.372
H	1508039.949	244756.286
I	1505572.209	243773.904
J	1507253.590	240368.356
K	1507900.290	238296.242
L	1509692.585	237002.696
M	1509978.266	237244.205
N	1509912.671	237323.601
O	1511481.688	238327.644
P	1512378.455	238297.749
Q	1512359.669	238979.449
R	1512326.914	240123.791
S	1513928.848	240125.130
T	1514942.929	241569.103

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៨៩៨ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម៖

១-លោក **អ៊ុយ សុធាវី**	ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៣ ជាអភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង
២-លោក **សឿម ម៉ុនរិទ្ធិ**	ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ២ ជាអភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

អន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងលោកស្រី **ម៉ននី រស្មី** ឋាននន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ជាអភិបាល នៃគណៈអភិបាលស្រុកក្រឡាញ់ ខេត្តសៀមរាប សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១៣កើតខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៩៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អគ្គលេខាធិការរដ្ឋសភា

សម្រេច

មាត្រា១.- បំពាក់មេដាយ**មាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងនិងអភិវឌ្ឍន៍សមិទ្ធផលនានា ក្នុងខេត្តកំពង់ធំនិងខេត្តត្បូងឃ្មុំកន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម	មាន សំអុល	ទីប្រឹក្សាសម្តេចប្រធានរដ្ឋសភា	ថវិកាចំនួន១០ ០០០ ដុល្លារ
២-ឯកឧត្តម	ង៉ាន់ ផុន	ជំនួយការសម្តេចប្រធានរដ្ឋសភា	ថវិកាចំនួន១០ ០០០ ដុល្លារ
៣-លោក	ឈុំ ឈុន	នាយកវិទ្យាល័យហ៊ុនសែនក្រវ៉ា	ថវិកាចំនួន១០ ០០០ ដុល្លារ
៤-លោក	ចាន់ រិទ្ធី	នៅរាជធានីភ្នំពេញ	ថវិកាចំនួន១០ ០០០ ដុល្លារ
៥-លោក	ឆេង យូសេង	នៅរាជធានីភ្នំពេញ	ថវិកាចំនួន១០ ០០០ ដុល្លារ

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការរដ្ឋសភា និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៩៧ អនក្រ.តត

អនុក្រឹត្យ
ស្ដីពីការជូនមេដាយការងារ
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១. បំពាក់មេដាយ**ការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការចំនួន ៨រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម៖

ក-មេដាយ**មាសការងារ**

-វរអគ្គានុរក្សថ្នាក់លេខ១ អ៊ុក ចន្ថា អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង

ខ-មេដាយ**ប្រាក់ការងារ**

-អនុរក្សថ្នាក់លេខ១ ទ្រី សេរីរតនៈ ប្រធានផ្នែក នៃពន្ធនាគារខេត្តកោះកុង

គ-មេដាយ **សំរឹទ្ធការងារ**

១-វរអគ្គានុរក្សថ្នាក់លេខ១ ដេង បូរ៉ា អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង
២-វរអគ្គានុរក្សថ្នាក់លេខ២ គ្រន សារិទ្ធ អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង
៣-វរអគ្គានុរក្សថ្នាក់លេខ២ សុខ ដារ៉ា អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង
៤-វរអគ្គានុរក្សថ្នាក់លេខ៣ អាន ហ៊ី អនុប្រធានការិយាល័យ នៃពន្ធនាគារខេត្តកោះកុង

៥-អនុរក្សថ្នាក់លេខ១ សុខ វណ្ណី អនុប្រធានផ្នែក នៃពន្ធនាគារខេត្តកោះកុង

៦-វរអគ្គានុរក្សថ្នាក់លេខ៣ ទារ គីមយីន មន្ត្រី នៃពន្ធនាគារខេត្តកោះកុង

មាត្រា២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/

ថ្ងៃ អង្គារ ១៣ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:៤៩៨.អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : តែងតាំងមន្ត្រីរាជការចំនួន ០២រូប ជាអភិបាល នៃគណៈអភិបាលស្រុក នៅក្នុងខេត្តរតនគិរី សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល ដូចមានរាយនាមខាងក្រោម:

១- លោក **សេត ហៃ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៤ ជាអភិបាលស្រុកកូនមុំ

២- លោក **ហេង សាឡឿន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ជាអភិបាលស្រុកវើនសៃ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៣កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០២១

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០៤៣ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០២១

ប្រកាសបង្កើតរោងចក្រ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងលិខិតលេខ៧២/២១ គ.វ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ ស្តីពីការវិនិយោគលើគម្រោងបង្កើតរោងចក្រផលិតធុងទឹកកក របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសំណើសុំប្រកាសបង្កើតរោងចក្រផលិតធុងទឹកកក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ក្រុមហ៊ុន ប៉ូលីមើ ប្លាស្ទីក ប្រដាក់ (ខេមបូឌា) ឯ.ក

សម្រេច

ប្រការ១៖ អនុញ្ញាតឱ្យក្រុមហ៊ុន ប៉ូលីមើ ប្លាស្ទីក ប្រដាក់ (ខេមបូឌា) ឯ.ក (**POLYMER PLASTIC PRODUCTS (CAMBODIA) CO., LTD.**) តំណាងដោយលោក **WEI, RICHEN** សញ្ជាតិចិន កាន់លិខិតឆ្លងដែនលេខ E54193904 ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ បង្កើតរោងចក្រផលិតធុងទឹកកក ដែលមានទីតាំងស្ថិតនៅភូមិជើងអក ឃុំលំហាច ស្រុកអង្គស្នួល ខេត្តកណ្តាល។

ឈ្មោះផលិតផល	**លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម** ISIC Rev.4 Code
ធុងទឹកកក	២២២០

ប្រការ២៖ ម្ចាស់រោងចក្រ ត្រូវលើកស្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

ស្លាកឈ្មោះរោងចក្រ៖ " **រោងចក្រផលិតធុងទឹកកក ប៉ូលីមើ ប្លាស្ទីក ប្រដាក់ (ខេមបូឌា) ឯ.ក** "

ប្រការ៣៖ ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងបទប្បញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

ប្រការ៤៖ មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ប្រការ៥៖ ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហនៅកន្លែងសមស្របណាមួយដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៦៖ ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៧៖ ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណីប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាព នៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៨៖ ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ៩៖ ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

ប្រការ១០៖ ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

